**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងភ្នំពេញ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ០៤៩ ចុះថ្ងៃទី ១១

ខែ មករា ឆ្នាំ ២០០០

**សាលក្រម**

លេខ ៣៤ "ឈ" ចុះថ្ងៃទី ២២

ខែ មិថុនា ឆ្នាំ ២០០០

*សាលក្រមនេះចូលជាស្ថាពរ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០០*

*ក្រឡាបញ្ជី* [redacted]

**បានឃើញ**

**ចៅក្រមជំនុំជំរះ** [redacted]

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការក្រុងភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។ បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការក្រុងភ្នំពេញ នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០០ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការ

**មេធាវី ឬអ្នកការពារក្តី**

លោក [redacted] មេធាវីជនជាប់ចោទ

ដើម្បីជំនុំជំរះលើឈ្មោះ **ម រ** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិ ខ្មែរ កើតនៅភូមិស្វាយ ឃុំស្វាយពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៥ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ ឪពុកឈ្មោះ **ន** (ស) ម្តាយឈ្មោះ **ឡ ម** (រ) ប្រពន្ធឈ្មោះ គ្មាន មានកូន ០នាក់ របររកស៊ីទៅផ្ទះ ទោសពីមុន *គ្មាន* ។

និង ឈ្មោះ **ន ច** ភេទប្រុស អាយុ ២០ឆ្នាំ ជាតិ ខ្មែរ មានមុខរបរ ជាងកាត់សក់ កើតនៅខេត្តកំពង់ស្ពឺ ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៣០ ក្នុងបុរីកីឡា សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ **ឥ ច** (រ) ម្តាយឈ្មោះ **ច ស** (ស) ប្រពន្ធ គ្មាន ទោសពីមុន *គ្មាន* ។

និង ឈ្មោះ **ជ រតន** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ កើតនៅខេត្តក្រចេះ ។ ទីលំនៅសព្វថ្ងៃផ្ទះសង់ថ្មី ផ្លូវ៦១៤ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ច **សម** ម្តាយឈ្មោះ ន **សខ** (រ) ប្រពន្ធ គ្មាន ទោសពីមុន *គ្មាន* ។

**ត្រូវចោទពីបទ** "លួច និងប្លន់" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០០ និងថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៤, ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ត្រូវឃុំខ្លួននៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ត សទ ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ ស្នាក់នៅផ្ទះលេខ ០៦E០ ផ្លូវ ៣០៧ ក្រុម ៥៥ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ មុខរបរ បញ្ជាការដ្ឋានទ័ពជើងគោក ។

-បានឃើញដីកាបញ្ជូនរឿងអោយស៊ើបសួរលេខ ០៤៨ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ របស់អយ្យការអមតុលាការក្រុងភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យមូលលេខ ១៥១៩ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០០ របស់តុលាការក្រុងភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២២៧ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ របស់អយ្យការអមតុលាការក្រុងភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ២០១៨ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ។

## នាពេលសវនាការ

-ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់លើឈ្មោះ **ច រ.ឆ ទ** និង ឈ្មោះ [redacted] **រតន** ។

-ជនល្មើសឈ្មោះ **ច រ** បានឆ្លើយថា ខ្លួនបានលួចរថយន្តពិតប្រាកដមែន កាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០០ វេលាម៉ោង ៣:០០ភ្លឺ ដើម្បីយកឡាននេះដើរលេង ពេលលួច គឺយកសោរកាច់ ក្រោយពីបានកាច់ហើយ ខ្លួនបានបើកឡានចេញទៅ ក្រៅពីនេះខ្លួនធ្លាប់លួចម៉ូតូម្តងដែរ ។ ចំពោះម្ចាស់ឡាន គឺខ្លួនធ្លាប់ស្គាល់ឡាននេះបានប្រគល់អោយម្ចាស់គេវិញហើយ ។

ពេលលួចមានគ្នា ០៣នាក់ គឺខ្លួន **ឆ ទ, ជទ រតន** ខ្លួនលួចនេះ គឺគោលបំណងយកជិះដើរលេង រួចហើយក៏បោះចោល ។ មុនថ្ងៃកើតហេតុ ខ្លួនធ្លាប់លួចម៉ូតូជាមួយ អា រ មិនស្គាល់អាស័យដ្ឋាននៅចុងឆ្នាំ ១៩៩៩ គឺម៉ូតូស៊ុយការ៉េ ពណ៌ក្រហម តែគេចាប់បាន ។

ដើមបណ្តឹងឈ្មោះ **គ ត** បានឆ្លើយថា ខ្លួនបានទុកឡាននៅខាងមុខផ្ទះជាប្រចាំ ដោយសំអាងមានគេយាមនៅក្បែរនោះ ហើយឡានរបស់ខ្លួនចាស់ផង នៅម៉ោង ៦:០០ព្រឹក ទើបដឹងថាបាត់រថយន្ត ហើយបានដាក់ពាក្យបណ្តឹងគ្រប់ស្ថាប័ន លុះម៉ោង ៨:០០ព្រឹក ទើបចាប់បាននៅប៉ុស្តិ៍សបឹងកក់ ២ ខ្លួនបានទិញរថយន្តនេះតម្លៃ ១.២០០ដុល្លា ខ្លួនសំណូមពរទាមទារជម្ងឺចិត្ត ៥០០ដុល្លារបស់របរនៅក្នុងរថយន្ត ២០០ដុល្លា។

តាមចម្លើយ **ច រ** បានឆ្លើយទៀតថា ចំពោះទ្រព្យសម្បត្តិ ខ្លួនមិនបានយកទេ ចំពោះអាវធំ និងមួក ខ្លួនជាអ្នកបោះចោល ចំពោះលុយក៏ខ្លួនសងគេដែរ ។

ចម្លើយជនល្មើសឈ្មោះ **ឆ ទ** បានឆ្លើយថា ខ្លួនធ្លាប់លួចគេម្តង គឺលួចរថយន្តនេះ គឺម៉ាកតូយ៉ូតា ក្រៅពីនេះ គឺខ្លួនមិនដែលលួចគេទេ ។

ចម្លើយជនឈ្មោះ [redacted] **រតន** បានឆ្លើយថា ខ្លួនទើបតែលួចបានម្តងនេះគត់ នៅពេលគេសួរចម្លើយខ្លួនបានឆ្លើយថា គឺបណ្តាលមកពីគេវាយធ្វើបាបខ្លួនខ្លាំងពេក ពេលលួចបានឡាននេះ គឺបើកទៅខូចនៅមុខឬស្សីកែវ ហើយក៏នាំគ្នាគេចទៅផ្ទះទៅ ។

-តំណាងអយ្យការធ្វើការសន្និដ្ឋានថា ជនល្មើសទាំង ០៣នាក់បានសារភាពចំពោះមុខតុលាការហើយសុំតម្កល់ការចោទប្រកាន់នៅដដែល គ្រាន់តែលើកលែងចោទប្រកាន់ពីបទលួច ។

-មេធាវីធ្វើសេចក្តីសន្និដ្ឋានថាជនល្មើសទាំង ០៣នាក់ បានសារភាពចំពោះមុខតុលាការហើយ សុំតម្កល់ការ

ចោទប្រកាន់នៅដដែល គ្រាន់តែលើកលែងចោទប្រកាន់ពីបទលួច ។

-មេធាវីធ្វើការសន្និដ្ឋានថា ឆ្លងតាមសវនាការ ជនល្មើសទាំង ០៣នាក់នេះ បានសារភាពហើយ ជនទាំង ០៣ នាក់នេះរៀនមិនបានគ្រប់គ្រាន់ មិនទាន់ចេះពិចារណា ហេតុនេះសូមលោកចៅក្រមបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង ។

-សំណូមពរ ជនល្មើសទាំង ០៣នាក់ជាចុងក្រោយថា សុំបន្ធូរបន្ថយទោសដល់ខ្លួន និង សុំដោះលែងដល់ខ្លួនទាំង ០៣ នាក់ ។

-ក្រោយពីបានស្តាប់ចម្លើយជនល្មើស

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានអយ្យការ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការយល់ឃើញថា

-ជនជាប់ចោទឈ្មោះ ម រ ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] រតន ភេទប្រុស អាយុ ១៨ឆ្នាំ និង ឈ្មោះ ឆ ទ ភេទប្រុស អាយុ ២២ឆ្នាំ ជានីតិជន អាចទទួលខុសត្រូវដោយខ្លួនឯងបាននូវរាល់អំពើប្រព្រឹត្តទាំងឡាយរបស់ខ្លួនចំពោះមុខច្បាប់ ។

-ជនជាប់ចោទឈ្មោះ ម រ, ជទ រតន, ឆ ទ ពិតជាបានប្រព្រឹត្តបទល្មើសប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០០ ពិតប្រាកដមែន ។

-ដើមបណ្តឹងឈ្មោះ ឱ សទ ថាខ្លួនទុករថយន្តនៅមុខផ្ទះលេខ ៦៨ ផ្លូវ ៣០៧ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០០ ត្រូវចោរលួចបាត់ តែត្រូវនគរបាលចាប់បានសងរថយន្ត នោះមកអោយខ្លួនវិញហើយ ខ្លួនសុំអោយតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

-វត្ថុតាងដកហូតបានមាន ពូថៅដៃដងឈើ ០១ ដែកសំរាប់កាច់សោរ០១ ។

-គ្មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះ ម រ. ជទ រតន.ឆ ទ ប្រព្រឹត្តបទល្មើសចោរកម្ម ។

-ជនរងគ្រោះឈ្មោះ ឱ សទ សំណូមពរទាមទារជម្ងឺចិត្ត ៥០០រៀល និង សម្ភារៈក្នុងឡាន ២០០$ ។

-តំណាងអយ្យការធ្វើការសន្និដ្ឋាន តម្កល់ការចោទប្រកាន់ដដែល និង សុំអោយតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## ហេតុដូច្នេះសំរេច

១-អោយជនជាប់ចោទឈ្មោះ ម រ, ជទ រតន, ឆ ទ រួចផុតពីការចោទប្រកាន់ ពីបទលួចប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ និង ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០០ និង ឆ្នាំ ១៩៩៩ ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ :

- ម រ ភេទប្រុស អាយុ ១៨ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៥ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

- **ជទ វគន** ភេទប្រុស អាយុ ១៨ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះសង់ថ្មី ផ្លូវលេខ ៦១៤ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក ក្រុងភំពេញ ។
- **ឆ ទ** ភេទប្រុស អាយុ ២០ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៣០ ក្នុងបូរីកីឡា សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៣ឆ្នាំ "បីឆ្នាំ" គិតពីថ្ងៃឃុំខ្លួន ពីបទប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០០ តាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-វត្ថុតាងមានពូថៅដងឈើ ១ ដង្កាប់ ១ ដែកកាច់សោរម៉ូតូ ១ ត្រូវរឹបអូស និងបំផ្លាញចោល ។

៤-បង្គាប់អោយឈ្មោះ **ច រ.ឆ ទ.ជទ វគន** រួមគ្នាសងថ្លៃជម្ងឺចិត្ត និងការបាត់បង់សម្ភារៈក្នុងរថយន្ត ចំនួន ៤០០$ ទៅអោយជនរងគ្រោះ **ឧ សទ** វិញ បើឈ្មោះនេះពុំព្រមសងត្រូវចាប់ដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ ។

៥-សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ០២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

ចៅក្រមជំនុំជំរះ

[redacted]